សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និង
លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហានក្ខត្តឧត្តម ពោរពេញដោយក្តីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ខ្ញុំនិងភរិយា សូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងសូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជ័យយុយីនយុ ដើម្បីបន្តដឹកនាំមាតុភូមិកម្ពុជាឱ្យមាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍកាន់តែរីកចម្រើនបន្តទៀត។

នាឱកាសដ៏មហាប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពកោតសរសើរ និងមានមោទនភាពបំផុតចំពោះ **សម្តេចធិបតី** ដែលជាមគ្គុទ្ទេសក៍បន្តវេនដ៏ធ្វើមពោរពេញទៅដោយសមត្ថភាព ភាពប៉ិនប្រសប់ និងមានមនសិការខ្ពស់ប្រកបដោយឆន្ទៈដ៏មោះមុតក្នុងការដឹកនាំមាតុភូមិកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។ ជាពិសេស ក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងរងការឈ្លានពានពីប្រទេសជិតខាង រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគ្រប់ស្ថាប័នពាក់ព័ន្ធនានា បានខិតខំពុះពារប្រយុទ្ធលើសមរភូមិការទូតដើម្បីការពារនូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានស្ថិតស្ថេរគង់វង្ស។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង **លោកជំទាវបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមប្រកបដោយ សុខភាពល្អបរិបូរ បញ្ញាញាណភ្លឺថ្លា ជ័យយុយីនយុ សូមបានសម្រេចនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីហ្សកឌឺហ្គោល សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh